គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)

Committee For Free And Fair Elections In Cambodia (COMFREL)

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

ខុមហ្វ្រែល COMFREL

P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org

**គណៈកម្មាធិការនាយក**
**BOARD OF DIRECTORS**

លោក **ធន សារាយ**
**Mr. THUN SARAY**
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន **ADHOC**

លោក **សុក សំអឿន**
**Mr. SOK Sam Oeun**
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក **CDP**

លោក **យឹម ប៉ូ**
**Mr. YIM Po** អគ្គលេខាធិការ
និង នាយក **CCPCR**

កញ្ញា **ស៊ីន ចាន់សែន**
**Mr. CHHIV You Meng**
ប្រធាន **KYA**

លោក **មុំ សារិន**
**Mr. MOM Sarin**
នាយក **HRCDO**

លោកស្រី **ពឹង យក់ហៀប**
**Mr. PEUNG Yok Hiep**
នាយិកា **LAC**

លោកស្រី **ទីវ សារាយេត**
**Ms. TIV Sarayet**
សហនាយិកា **WMC**

កញ្ញា **សយ សារា វឌ្ឍនី**
**Miss. SAY Sara Vathany**
នាយិកា **CWCC**

លោក **គឹម សុវណ្ណ**
**Mr. KIM Sovann**
នាយក **VIGILANCE**

លោក **អាង ច័ន្ទឫទ្ធិ**
**Mr. ANG Chanrith**
នាយក **KKKHRO**

លោក **យង់ គិមអេង**
**Mr. YONG Kim Eng**
នាយក **PDP-Center**

លោក **ភួង សិទ្ធិ**
**Mr. PHUONG Sith**

លោក **សឺន សែត**
**Mr. SEN Set**

ស.ប្រ.ក.៣/លេខ ១០/០៩ គ.ប.ស.យ/អ.ក

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលស្រាវជ្រាវទៅលើបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត

*ភ្នំពេញ, ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៩*

ការស្រាវជ្រាវរបស់**គណៈកម្មាធិការខុមហ្វ្រែល**ទៅលើបញ្ជីបោះឆ្នោត ការចុះឈ្មោះបោះឆ្នោត និងអ្នកមានសិទ្ធិបោះឆ្នោត[១] រកឃើញថា ការធ្វើកំណែទម្រង់ការចុះឈ្មោះបោះឆ្នោត និងការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត ជាពិសេសនៅឆ្នាំបោះឆ្នោត គឺជាការចាំបាច់ដើម្បីធានាសិទ្ធិរបស់អ្នកបោះឆ្នោតទាំងអស់អាចបោះឆ្នោតបានដោយគ្មានឧបសគ្គ និងការលំបាក។

ការស្រាវជ្រាវដែលមានកិច្ចសហការជាមួយគណៈកម្មាធិការនិកហ្វិច មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព និងសមាគមយុវជនខ្មែរធ្វើឡើងកាលពីខែ កុម្ភៈ ដល់ខែមិថុនា ឆ្នាំ ២០០៩ ទៅលើអ្នកមានសិទ្ធិបោះឆ្នោតចំនួន **៨.៦៧៨ នាក់ ទូទាំងប្រទេស** ក្រោមការគាំទ្រថវិកាពីម្ចាស់ជំនួយដូចជា កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP), ស្ថានទូតអង់គ្លេស, Forum Syd និង NPA ដែលជួយឱ្យការស្រាវជ្រាវនេះមានដំណើរការ។ វិធីសាស្ត្រនៃការការស្រាវជ្រាវ និងទំហំសំណាកត្រូវបានកំណត់យកកំហុសធំបំផុតក្នុងការវាយតំលៃ (Margin of error) +/- ៥% និងកំរិតជឿជាក់ (Confidence level) ៩៥%។

ការស្រាវជ្រាវបានបង្ហាញថា អ្នកមានសិទ្ធិបោះឆ្នោតប្រមាណ **៤៤០.000**[២] នាក់បានចេញទៅបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៨ ក៏ប៉ុន្តែមិនអាចបោះឆ្នោតបាន ដោយសារជួបឧបសគ្គមួយចំនួន **ជាពិសេសការរកឈ្មោះ ឬការិយាល័យបោះឆ្នោតមិនឃើញ** បើទោះបីជាពួកគាត់ធ្លាប់បោះឆ្នោតក្នុងឆ្នាំ ២០០៣ ឬ/និង ២០០៧ ក៏ដោយ។ ការស្រាវជ្រាវនេះក៏រកឃើញដែរថា នៅក្នុងការបោះឆ្នោតឆ្នាំ ២០០៨ កន្លងមកនេះ

---

[១] អ្នកមានសិទ្ធិបោះឆ្នោត គឺសំដៅទៅលើប្រជាពលរដ្ឋដែលមានអាយុ ១៨ ឆ្នាំឡើងទៅ ហើយដែលសិទ្ធិបោះឆ្នោតរបស់គាត់មិនត្រូវបានដកហូត

[២] ចំនួននេះអាចតិចជាង ៤៤០.000 នាក់ ប្រសិនបើបញ្ជីបោះឆ្នោតឆ្នាំ ២០០៧ សម្រាប់ការបោះឆ្នោតឆ្នាំ ២០០៨ មិនមានភាពសុក្រឹត ១០០% ទេ (មានឈ្មោះអ្នកបោះឆ្នោតស្ទួន ឬ/និង មានឈ្មោះខ្មោច)

មានប្រជាពលរដ្ឋប្រមាណ **៤៤០.០០០ នាក់ដែរដែលបានប្រើប្រាស់ទម្រង់ ១០១៨** ដ៏ចម្រូងចម្រាស ដើម្បីបោះឆ្នោត។ ហើយអ្នកមានសិទ្ធិបោះឆ្នោត ៩០,៧% បានទទួលប័ណ្ណព័ត៌មានអ្នកបោះឆ្នោត។

ដោយឡែកការស្រាវជ្រាវ និងការធ្វើ**សវនកម្មបញ្ជីបោះឆ្នោតឆ្នាំ ២០០៨** រកឃើញថា ភាពត្រឹមត្រូវនៃបញ្ជីបោះឆ្នោតមានត្រឹមតែ **៦៣,៤០%** (ឈ្មោះ ភេទ និងអាយុរបស់អ្នកបោះឆ្នោត ដូចទៅនឹងបញ្ជី បោះឆ្នោតឆ្នាំ ២០០៨) ហើយអ្នកមានសិទ្ធិបោះឆ្នោត **១៨,៥០%** មិនមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត។

លោក **ធន សារាយ** ប្រធានគណៈកម្មាធិការនាយកខុមហ្វ្រែល និងជាប្រធានសមាគមសិទ្ធិមនុស្ស **អាដហុក** បានថ្លែងនៅក្នុងសន្និសីទសារព័ត៌មានស្តីពី **"លទ្ធផលស្រាវជ្រាវទៅលើបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត"** នៅថ្ងៃនេះថា *"គ្មានហេតុផលណាដែលការចុះឈ្មោះ និងបញ្ជីបោះឆ្នោតបង្កការលំបាកដល់អ្នកមានសិទ្ធិបោះឆ្នោតនោះទេ។ ការចុះឈ្មោះបោះឆ្នោត និងបញ្ជីបោះឆ្នោតមួយដែលមានលក្ខណៈច្បាស់លាស់ និងត្រឹមត្រូវពេញលេញជាផ្នែកដ៏សំខាន់នៃដំណើរបោះឆ្នោត ប្រកបដោយសេរី និងយុត្តិធម៌។ ការបង្កើតនីតិវិធីសំរាប់ការចុះឈ្មោះ និងបញ្ជីបោះឆ្នោតត្រូវតែមានប្រសិទ្ធិភាព ឥតលំអៀង និងឥតមានការរើសអើង។"*

ការស្រាវជ្រាវនេះ ក៏បានផ្តល់អនុសាសន៍ឱ្យធ្វើកំណែទម្រង់ដល់បញ្ជីបោះឆ្នោត ការចុះឈ្មោះបោះឆ្នោត និងការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតដោយ រាល់ការលុបឈ្មោះអ្នកបោះឆ្នោតដែលប្តូរទីលំនៅត្រូវតែមានឯកសារបញ្ជាក់គ្រប់គ្រាន់ពីសាមីខ្លួន ហើយការលុបឈ្មោះអ្នកស្លាប់ត្រូវមានឯកសារបញ្ជាក់ពីក្រុមគ្រួសារ។ ជាងនេះទៅទៀត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (**គ.ជ.ប**) ដោយសហការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមកពីគណបក្សនយោបាយផ្សេងគ្នា និងអាជ្ញាធរមូលដ្ឋានផ្សេងៗទៀត ត្រូវទទួលខុសត្រូវរៀបចំការចុះឈ្មោះអ្នកបោះឆ្នោត និងធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតពិសេសមួយសម្រាប់ការបោះឆ្នោតរៀងរាល់ការបោះឆ្នោត ហើយរយៈពេលការចុះឈ្មោះអ្នកបោះឆ្នោត និងធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតពិសេសនេះគួរត្រូវបន្ថែមដល់១២០ថ្ងៃ ដើម្បីឱ្យប្រជាពលរដ្ឋមានពេលវេលាច្រើនចុះឈ្មោះបោះឆ្នោត និងពិនិត្យកែតម្រូវទិន្នន័យ ក្នុងបញ្ជីបោះឆ្នោត។

ការស្រាវជ្រាវបង្ហាញថា ការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតត្រូវតែបន្តអនុវត្ត ក៏ប៉ុន្តែនីតិវិធីនៃការចែកក៏ដូចជាលក្ខណៈនៃប័ណ្ណព័ត៌មានត្រូវធ្វើការកែសម្រួល។ អ្នកបោះឆ្នោតម្នាក់ៗត្រូវតែមានប័ណ្ណព័ត៌មានបោះឆ្នោតដើម្បីដោះស្រាយឧបសគ្គធំៗនានានៅការិយាល័យបោះឆ្នោត ដែលជួបបញ្ហារកឈ្មោះ ឬការិយាល័យបោះឆ្នោតរបស់ខ្លួនមិនឃើញ។ ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតត្រូវបានផលិតដោយមានអ៊ុតប្លាស្ទិក ហើយត្រូវមានព័ត៌មានអ្នកបោះឆ្នោតជាពិសេសការិយាល័យ និងមណ្ឌលបោះឆ្នោត **"ជាអចិន្ត្រៃយ៍"** ហើយ **គ.ជ.ប**

ចំណែកការប្រើប្រាស់ទម្រង់ ១០១៨ សម្រាប់ការបោះឆ្នោត ក្រសួងមហាផ្ទៃគួរព្យាយាមឱ្យអស់លទ្ធភាព ដើម្បីចេញ និងចែកអត្តសញ្ញាណប័ណ្ណខ្មែរដល់គ្រប់ប្រជាពលរដ្ឋកម្ពុជាឱ្យបានយ៉ាងយូរត្រឹមឆ្នាំ២០១១។ ប្រសិនបើក្រសួងមហាផ្ទៃមិនអាចចេញ និងចែកអត្តសញ្ញាណប័ណ្ណឱ្យពលរដ្ឋខ្មែរបាន១០០%ទេ នោះត្រូវមានវិធានការ២យ៉ាងៈ ១) ក្រសួងមហាផ្ទៃ និងគ.ជ.ប គួរធ្វើសេចក្តីណែនាំ និងផ្សព្វផ្សាយជាសាធារណៈថា អត្តសញ្ញាណប័ណ្ណដែលផុតកាលកំណត់ អាចប្រើប្រាស់ជាឯកសារអត្តសញ្ញាណដើម្បីបោះឆ្នោតបាន។ ២) ទម្រង់ ១០១៨ ឬឯកសារអត្តសញ្ញាណបណ្តោះអាសន្នផ្សេងទៀតនៅតែចាំបាច់សម្រាប់អ្នកបោះឆ្នោត។ ទោះបីយ៉ាងណា ទម្រង់១០១៨ គួរតែត្រូវប្តូរទៅជាប័ណ្ណបោះឆ្នោតបណ្តោះអាសន្នវិញ។ ហើយការចេញប័ណ្ណនេះត្រូវឱ្យមានតម្លាភាព និងត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ។

លោក **សុក សំអឿន** អនុប្រធានគណៈកម្មាធិការនាយកខុមហ្វ្រែល និងជាប្រធានអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជាបានលើកឡើងថា *"ការរកឃើញ និងអនុសាសន៍ទាំងនេះនឹងត្រូវយកទៅពិភាក្សានៅពេលខាងមុខទៀត ដូចជានៅក្នុងសិក្ខាសាលាស្តីពីកំណែទម្រង់បោះឆ្នោត នៅខែសីហា ឆ្នាំ២០០៩ ដែលចាត់ចែងដោយវិទ្យាស្ថានជាតិប្រជាធិបតេយ្យសម្រាប់កិច្ចការអន្តរជាតិ (NDI) និងអង្គការសង្គមស៊ីវិល និងក្នុងសន្និសីទជាតិស្តីពី ការចុះឈ្មោះបោះឆ្នោតដែលរៀបចំដោយទីប្រឹក្សាសហគមន៍អឺរ៉ុប (EC) សម្រាប់ គ.ជ.ប នៅក្នុងខែកញ្ញា ឆ្នាំ២០០៩ ហើយនឹងរៀបចំធ្វើសំណើវិសោធនកម្មទៅលើនីតិវិធី និងច្បាប់បោះឆ្នោត។"*

សម្រាប់របាយការណ៍លទ្ធផលលម្អិតនៃការស្រាវជ្រាវនេះ សូមចូលទៅកាន់គេហទំព័រខុមហ្វ្រែលៈ www.comfrel.org

*សម្រាប់ព័ត៌មានផ្សេងៗសូមទាក់ទងៈ*


- លោក **គល់ បញ្ញា** នាយកប្រតិបត្តិ ខុមហ្វ្រែល ទូរស័ព្ទៈ **០១២ ៩៤២ ០១៧**
- លោក **សុខ ពិនូរ្យ** អ្នកសម្របសម្រួលស្តីទីផ្នែកអង្កេត ខុមហ្វ្រែល ទូរស័ព្ទៈ **០៨៩ ៥២៥ ៤៤៦**